**សលាកបត្រព័ត៌មាន ៖ ការចូលរួមជាមួយអ្នករាយការណ៍ពិសេសស្តីពីសិទ្ធិជួបប្រជុំដោយសន្តិវិធីនិងចងក្រងសមាគម**

**ទិដ្ឋភាពរួម** ៖ អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិជួបប្រជុំដោយសន្តិវិធី និងចងក្រងសមាគម ("អ្នករាយការណ៍ពិសេស") គឺជាយន្តការមួយរបស់អង្គការសហប្រជាជាតិដែលមានអាណត្តិផ្តល់អនុសាសន៍អំពីសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងចងក្រងសមាគមនៅជុំវិញពិភពលោកក្នុងគោលបំណងធ្វើឱ្យប្រសើរនូវការការពារ និងការលើកកម្ពស់សិទ្ធិទាំងនេះ។ សលាកបត្រព័ត៌មាននេះផ្តល់ជាមគ្គុទេសក៍សម្រាប់សង្គមស៊ីវិលក្នុងការចូលរួមជាមួយអ្នករាយការណ៍ពិសេស។ សលាកបត្រព័ត៌មាននេះគូសបញ្ជាក់អំពីតួនាទីនិងអាណត្តិការងាររបស់អ្នករាយការណ៍ពិសេស និងលើកឡើងអំពីដំណាក់កាលជាក់លាក់ទាក់ទងនឹងវិធីទំនាក់ទំនង និងការចូលរួមជាមួយការងាររបស់អ្នករាយការណ៍ពិសេស។

## ១. សេចក្តីផ្តើម

សិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធីនិងចងក្រងសមាគមគឺជាគ្រឹះដ៏សំខាន់នៃច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិជួបប្រជុំដោយសន្តិវិធីនិងចងក្រងសមាគម ("អ្នករាយការណ៍ពិសេស") គឺជានីតិវិធីពិសេសនៃអង្គការសហប្រជាជាតិដែលមានអាណត្តិបំពេញមុខងារផ្សេងៗក្នុងគោលបំណងលើកកម្ពស់ និងការពារសិទ្ធិមនុស្សនៅទូទាំងពិភពលោក។[1] ការចូលរួមជាមួយអ្នករាយការណ៍ពិសេសអាចទទួលអត្ថប្រយោជន៍ផ្សេងៗសម្រាប់សង្គមស៊ីវិលកម្ពុជាដែលព្យាយាមការពារ និងលើកកម្ពស់សិទ្ធិជួបប្រជុំដោយសន្តិវិធី និងចងក្រងសមាគម ក្នុងនោះមានដូចជាការទាញចំណាប់អារម្មណ៍លើយន្តការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ ភ្ជាប់ទៅនឹងការរំលោភបំពានសិទ្ធិជួបប្រជុំនិងចងក្រងសមាគមក្នុងប្រទេសកម្ពុជា ការលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីសេរីភាពក្នុងការជួបប្រជុំនិងចងក្រងសមាគម និងការចូលរួមចំណែកក្នុងការបង្កើតបទដ្ឋានអន្តរជាតិទាក់ទងនឹងសេរីភាពក្នុងការជួបប្រជុំនិងចងក្រងសមាគម។ សលាកបត្រព័ត៌មាននេះផ្តល់ជាមគ្គុទេសក៍ដល់សង្គមស៊ីវិល អំពីតួនាទីនិងអាណត្តិការងារ និងវិធីដែលអង្គការសង្គមស៊ីវិលអាចធ្វើទំនាក់ទំនងជាមួយអ្នករាយការណ៍ពិសេស។

សលាកបត្រព័ត៌មាននេះចងក្រងឡើងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") ដែលជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ និងមិនចូលបក្ខសម្ព័ន្ធដែលធ្វើការងារដើម្បីលើកកម្ពស់និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្សនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

[1] សម្រាប់ព័ត៌មានបន្ថែមអំពីអាណត្តិរបស់អ្នករាយការណ៍ពិសេស សូមមើលឯកសារព័ត៌មានរបស់ ម.ស.ម.ក អំពីអាណត្តិការងាររបស់អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិជួបប្រជុំដោយសន្តិវិធីនិងចងក្រងសមាគម (ខែឧសភា ឆ្នាំ២០២០) https://bit.ly/33g3sgt។

**តើនីតិវិធីពិសេសនៃអង្គការសហប្រជាជាតិជាអ្វី ?** នីតិវិធីពិសេសនៃក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ គឺជាអ្នកជំនាញសិទ្ធិមនុស្សឯករាជ្យដែលមានអាណត្តិក្នុងការរាយការណ៍ ឃ្លាំមើល និងផ្តល់អនុសាសន៍អំពីសិទ្ធិមនុស្សតាមវិស័យជាក់លាក់ ឬក្នុងប្រទេសណាមួយ។[2] ដើម្បីសម្រេចតាមគោលបំណងនេះ អ្នកកាន់អាណត្តិត្រូវបានប្រគល់សិទ្ធិឱ្យធ្វើទស្សនកិច្ចនានាក្នុងប្រទេស និងបញ្ជូនសារទំនាក់ទំនងទៅកាន់រដ្ឋពាក់ព័ន្ធក្នុងការរំលោភសិទ្ធិមនុស្ស។ អ្នកកាន់អាណត្តិមានតួនាទីខុសៗគ្នា ដូចជា "អ្នករាយការណ៍ពិសេស" "អ្នកជំនាញឯករាជ្យ" "តំណាងពិសេស" និង " ក្រុមការងារ"។ ក្នុងពេលនៃការតាក់តែងសលាកបត្រព័ត៌មាននេះ អ្នកកាន់អាណត្តិនៃនីតិវិធីពិសេសតាមវិស័យមានចំនួន **៤៤** រូប និងអ្នកកាន់អាណត្តិប្រចាំប្រទេសមានចំនួន **១២** រូប។[3]

## ២. តួនាទី និងអាណត្តិការងាររបស់អ្នករាយការណ៍ពិសេស

អ្នករាយការណ៍ពិសេសត្រូវបានបង្កើតឡើងនៅឆ្នាំ២០១០ តាមរយៈសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សឆ្នាំ២០១០ លេខ ១៥/២១ និងទទួលអាណត្តិបំពេញមុខងារផ្សេងៗក្នុងគោលបំណងលើកកម្ពស់ និងការពារសិទ្ធិជួបប្រជុំនិងចងក្រងសមាគម។ អ្នករាយការណ៍ពិសេស ទទួលអាណត្តិបំពេញការងារដូចខាងក្រោម៖[4]

→ ប្រមូលព័ត៌មានពាក់ព័ន្ធទាំងអស់ មានដូចជា ការអនុវត្តថ្នាក់ជាតិ និងបទពិសោធន៍នានាទាក់ទងនឹងការលើកកម្ពស់ និងការការពារសិទ្ធិជួបប្រជុំនិងចងក្រងសមាគម ដើម្បីសិក្សាអំពីនិន្នាការ វឌ្ឍនភាព និងបញ្ហាប្រឈមទាក់ទងនឹងការអនុវត្តសិទ្ធិទាំងនេះ និងផ្តល់អនុសាសន៍អំពីវិធីសាស្ត្រ និងមធ្យោបាយក្នុងការធានាដល់កិច្ចការពារសិទ្ធិជួបប្រជុំនិងចងក្រងសមាគម។

→ ចងក្រងរបាយការណ៍តាមវិស័យ ដោយពិនិត្យមើលលើទិដ្ឋភាពរបស់រដ្ឋនានា បរិយាយពិស្តារអំពីក្របខ័ណ្ឌសិទ្ធិជួបប្រជុំនិងចងក្រងសមាគម និងការអនុវត្តល្អប្រសើរក្នុងការលើកកម្ពស់ និងការការពារសិទ្ធិជួបប្រជុំនិងចងក្រងសមាគម។

→ ស្វែងរក ទទួល និងឆ្លើយតបព័ត៌មាននានាពីសំណាក់រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធទាក់ទងនឹងសិទ្ធិជួបប្រជុំនិងចងក្រងសមាគម។

→ បញ្ចូលទស្សនៈយេនឌ័រនៅក្នុងអាណត្តិការងារ។

→ ផ្តល់ជាតុចូលលើជំនួយបច្ចេកទេស ឬអនុសាសន៍របស់ការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សចំពោះសិទ្ធិជួបប្រជុំនិងចងក្រងសមាគម។

[2] ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស អ.ស.ប សេចក្តីណែនាំអំពីនីតិវិធីពិសេសនៃក្រុមប្រឹក្សាសិទ្ធិមនុស្ស https://bit.ly/3k4piKG។

[3] សម្រាប់បញ្ជីឈ្មោះអ្នកកាន់អាណត្តិនៃនីតិវិធីពិសេសអង្គការសហប្រជាជាតិបច្ចុប្បន្ន និងអាសយដ្ឋានទំនាក់ទំនងរបស់ពួកគាត់ សូមមើល បញ្ជីនៃនីតិវិធីពិសេស (ខែកក្កដា ឆ្នាំ២០២០) https://bit.ly/33j3dl7។

[4] មហាសន្និបាតនៃអង្គការសហប្រជាជាតិ "សេចក្តីសម្រេចលេខ ១៥/២១ សិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងចងក្រងសមាគម ថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១០ UN Doc A/HRC/RES/15/20, https://bit.ly/33csTQh។

→ រាយការណ៍អំពីករណីរំលោភបំពាននានាដែលកើតឡើងនៅគ្រប់ទីកន្លែង ជុំវិញសិទ្ធិជួបប្រជុំនិងចងក្រងសមាគម ព្រមទាំង ការរើសអើង ការគំរាមកំហែង ឬអំពើហិង្សា ការឃាត់ ការផ្តន្ទាទោស ការធ្វើទុក្ខបុកម្នេញ ឬការព្យាបាទលើបុគ្គលដែលអនុវត្តសិទ្ធិទាំងនេះ។

→ ឆ្លើយតបទៅនឹងករណីនីមួយៗ និងករណីរំលោភបំពានលើសិទ្ធិជួបប្រជុំ និងចងក្រងសមាគម។

អាណត្តិការងាររបស់អ្នករាយការណ៍ពិសេសត្រូវបានបន្តរយៈពេល ៣ ឆ្នាំទៀតក្នុងឆ្នាំ២០១៣ និងឆ្នាំ២០១៦។[5] អ្នកកាន់អាណត្តិបច្ចុប្បន្ន គឺលោក **ក្លេម៉ិន នីយ៉ាឡេតសូហ្ស៊ី វ៉ូល** ទទួលការតែងតាំងក្នុងខែមីនា ឆ្នាំ២០១៨។[6]

## ៣.អត្ថប្រយោជន៍នៃការចូលរួមជាមួយអាណត្តិនៃនីតិវិធីពិសេសអង្គការសហប្រជាជាតិ

ការចូលរួមជាមួយអ្នកកាន់អាណត្តិនៃនីតិវិធីពិសេស រួមទាំងអ្នករាយការណ៍ពិសេស អាចមានអត្ថប្រយោជន៍ជាច្រើនសម្រាប់តួអង្គសង្គមស៊ីវិល។ អត្ថប្រយោជន៍ទាំងនោះ រួមមាន៖

- លើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីបញ្ហាណាមួយ ដូចជាសិទ្ធិជួបប្រជុំនិងចងក្រងសមាគម
- ទាញការចាប់អារម្មណ៍លើករណីដែលកើតឡើងក្នុងប្រទេសជាក់លាក់ណាមួយ ដូចជា ករណីរំលោភសិទ្ធិជួបប្រជុំនិងចងក្រងសមាគមដែលកើតឡើងក្នុងប្រទេសកម្ពុជា ព្រមទាំងយន្តការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ
- ជំរុញឱ្យរដ្ឋនានា ដូចជា ប្រទេសកម្ពុជាផ្តល់ទទ្បីករណ៍លើវិធានការរបស់ខ្លួនទាក់ទងនឹងបញ្ហាជាក់លាក់អ្វីមួយ ដោយផ្អែកតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ
- ចូលរួមជាមួយសហគមន៍ជាតិ និងអន្តរជាតិ ជំរុញអោយមានដំណោះស្រាយលើបញ្ហាជាក់លាក់អ្វីមួយ ដូចជា ការរំលោភលើសិទ្ធិជួបប្រជុំនិងចងក្រងសមាគម
- ផ្តល់ឱកាសដើម្បីចូលរួមក្នុងកិច្ចពិភាក្សាទាក់ទងនឹងការអនុវត្តនិងការបង្កើតបទដ្ឋានសិទ្ធិមនុស្ស និង
- ជួយជំរុញឱ្យមានដំណោះស្រាយលើបញ្ហារំលោភបំពានណាមួយ។

## ៤. ការចូលរួមរបស់សង្គមស៊ីវិលជាមួយអ្នករាយការណ៍ពិសេស

ក្នុងនាមជាយន្តការសិទ្ធិមនុស្សមួយនៃអង្គការសហប្រជាជាតិ ផ្នែកសំខាន់នៃអាណត្តិការងាររបស់អ្នករាយការណ៍ពិសេស គឺដើម្បីចូលរួមជាមួយបុគ្គលនានា និងសង្គមស៊ីវិលក្នុងការដោះស្រាយក្តីបារម្ភទាក់ទងនឹងការលើកកម្ពស់ និងការការពារសិទ្ធិជួបប្រជុំនិងចងក្រងសមាគម។ មានវិធីមួយចំនួនដែលសង្គមស៊ីវិលអាចចូលរួមជាមួយអ្នករាយការណ៍ពិសេសបាន ដូចជាតាមរយៈការបញ្ជូនសារទំនាក់ទំនង និងការឆ្លើយតបទៅនឹងសំណើសុំធាតុចូលដើម្បីធ្វើវិភាគទានក្នុងរបាយការណ៍តាមវិស័យ។

### *១. ការបញ្ជូនសារទំនាក់ទំនង*

[5] សូមមើលប័ណ្ណព័ត៌មានស្តីពីអាណត្តិរបស់អ្នករាយការពិសេស នៃការិយាល័យនៃឧត្តមស្នងការសិទ្ធិមនុស្ស https://bit.ly/2FeJScE ។

[6] សូមមើលប័ណ្ណព័ត៌មានអំពីអាណត្តិរបស់លោក ក្លេម៉ីន នីយ៉ាឡេតសូហ្ស៊ី វ៉ូល អ្នករាយការពិសេសស្តីពីសិទ្ធិជួបប្រជុំដោយសន្តិវិធីនិងចងក្រងសមាគម https://bit.ly/32gCshW ។

យន្តការនីតិវិធីពិសេសអាចពិនិត្យលើការលើកឡើងជុំវិញករណីរំលោភបំពានសិទ្ធិមនុស្ស និងធ្វើអន្តរាគមន៍ដោយផ្ទាល់ជាមួយរដ្ឋាភិបាលលើការលើកឡើងទាំងនេះ ដែលកើតឡើងនៅក្នុងអាណត្តិរបស់ខ្លួន។ អ្នកកាន់អាណត្តិត្រូវបានផ្តល់សិទ្ធិឱ្យទទួលសារទំនាក់ទំនងពីជនរងគ្រោះនៃករណីរំលោភសិទ្ធិមនុស្ស និងពីតួអង្គសង្គមស៊ីវិលតាមការដឹងឮដោយផ្ទាល់ និងពីប្រភពដែលអាចទុកចិត្តបានជុំវិញករណីរំលោភបំពានសិទ្ធិជួបប្រជុំ និងចងក្រងសមាគម។ អ្នករាយការណ៍ពិសេសពិនិត្យមើលលើសារទំនាក់ទំនងនានាដែលទាក់ទងផ្ទាល់នឹងការរំលោភបំពានសិទ្ធិជួបប្រជុំ និងចងក្រងសមាគម ហើយការដាក់ពាក្យបណ្តឹងណាមួយទាក់ទងនឹងអាណត្តិការងាររបស់អ្នករាយការណ៍ពិសេសនឹងត្រូវដាក់ទៅកាន់អ្នករាយការណ៍ពិសេសដោយផ្ទាល់។

**ករណីដែលតួអង្គសង្គមស៊ីវិលអាចធ្វើទំនាក់ទំនងជាមួយអ្នករាយការណ៍ពិសេស ៖**

- ការប្រើប្រាស់កម្លាំងហួសហេតុលើការតវ៉ានានា
- អាជ្ញាធររារាំង ឬទប់ស្កាត់ការជួបប្រជុំដោយសន្តិវិធី
- ការឃាយីផ្នែករាងកាយ និងតុលាការលើអ្នកចូលរួមការប្រមូលផ្តុំ ដូចជា សមាជិកសមាគម ឬសហជីពជាដើម
- ការរឹតត្បិតលើការបង្កើត ការចូលជាសមាជិក ឬការចូលរួមក្នុងសមាគម មានដូចជា គណបក្សនយោបាយ និងសហជីព ជាដើម
- សេចក្តីព្រាងច្បាប់ ឬច្បាប់ និងគោលនយោបាយបច្ចុប្បន្នរឹតត្បិតលើសិទ្ធិជួបប្រជុំ និងចងក្រងសមាគម

ទំនាក់ទំនងអាចមានខ្លឹមសារគ្របដណ្តប់ទៅលើបញ្ហាផ្សេងៗ ជាច្រើន រួមមាន ករណីជាក់ស្តែង, និន្នាការសិទ្ធិមនុស្សទូទៅ, ករណីប៉ះពាល់ដល់ក្រុម, ឬសហគមន៍ណាមួយ ឬខ្លឹមសារនៃសេចក្តីព្រាងច្បាប់ ឬច្បាប់ជាធរមាន គោលនយោបាយ ឬការអនុវត្តដែលចាត់ទុកថាពុំអនុលោមពេញលេញជាមួយច្បាប់ និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។ តួអង្គសង្គមស៊ីវិលក៏អាចដើរតួនាទីក្នុងការទប់ស្កាត់តាមរយៈការផ្តល់ព័ត៌មានជូនអ្នកកាន់អាណត្តិអំពីច្បាប់ គោលនយោបាយថ្មីៗ និងការអនុវត្តនានាផងដែរ ប្រសិនបើច្បាប់នោះត្រូវបានអនុម័ត ឬចូលជាធរមាន អាចនាំឱ្យមានការរំលោភសិទ្ធិមនុស្ស។

ជាទូទៅ តួអង្គសង្គមស៊ីវិលគួរផ្តល់ព័ត៌មានច្បាស់លាស់ អាចជឿទុកចិត្តបាន និងពិស្តារទាក់ទងនឹងករណីរំលោភបំពានសិទ្ធិមនុស្ស។ សូមមើលខាងក្រោមថាតើព័ត៌មានណាខ្លះដែលត្រូវបញ្ចូលក្នុងទំនាក់ទំនង។[7]

**សម្រាប់ទំនាក់ទំនងអាចធ្វើឡើងតាមរយៈទម្រង់នេះ** https://spsubmission.ohchr.org/។ **ដោយឡែកសម្រាប់របាយការណ៍នានាអាចធ្វើតាមរយៈសារអេឡិចត្រូនិច** urgent-action@ohchr.org។

[7] សម្រាប់ព័ត៌មានបន្ថែមអំពីការបញ្ជូនសារទំនាក់ទំនង និងព័ត៌មានដែលត្រូវលើកឡើងក្នុងសារទំនាក់ទំនង សូមមើលប័ណ្ណព័ត៌មានស្តីពី "ទំនាក់ទំនង" ផលិតដោយ ការិយាល័យនៃឧត្តមស្នងការសិទ្ធិមនុស្ស អ.ស.ប https://bit.ly/3k6N5to។

**ប្រភេទព័ត៌មានដែលត្រូវបញ្ចូលក្នុងទំនាក់ទំនង**[8]

សម្រាប់បណ្ដឹងត្រូវបញ្ចូលនូវព័ត៌មាន ដូចខាងក្រោម៖
១. អត្តសញ្ញាណរបស់ជនរងគ្រោះ(ច្រើន) ។
២. អត្តសញ្ញាណរបស់ជនប្រព្រឹត្ត (ប្រសិនជាស្គាល់)។
៣. អត្តសញ្ញាណរបស់បុគ្គល (ច្រើន) ឬអង្គការ (ច្រើន)ដែលជាអ្នកបញ្ជូនសារទំនាក់ទំនង។
៤. កាលបរិច្ឆេទ និងទីកន្លែង ហើយនិងសេចក្ដីពិពណ៌នាលម្អិតអំពីស្ថានភាពនៃឧបទ្ទវហេតុ (ច្រើន) ឬ ករណីរំលោភបំពាន។
៥. វិធានការដែលអាជ្ញាធរពាក់ព័ន្ធឆ្លើយតបទៅនឹងស្ថានភាពនោះ។
៦. ព័ត៌មានផ្សេងៗដែលអាចបញ្ជាក់បន្ថែមទៀតអំពីបរិបទនៃការរំលោភបំពាន។
៧. ការបញ្ជាក់ព័ត៌មានច្បាស់លាស់ ថាតើជនរងគ្រោះ ឬតំណាងយល់ព្រមឱ្យបង្ហាញឈ្មោះរបស់ពួកគេក្នុងសារទំនាក់ទំនងនានា ឬក៏បង្ហាញក្នុងរបាយការណ៍សិទ្ធិមនុស្សជាសាធារណៈរបស់អង្គការសហប្រជាជាតិ ។

**តើអ្នករាយការណ៍ពិសេសនឹងធ្វើដូចម្ដេចចំពោះព័ត៌មាននេះ** ?

អាស្រ័យលើខ្លឹមសារនៃទំនាក់ទំនង អ្នករាយការណ៍ពិសេសអាចធ្វើសេចក្ដីសម្រេចចិត្តក្នុងការអន្តរាគមន៍ ឬចាត់វិធានការតាមសារទំនាក់ទំនង។ ក្នុងនោះ រួមមាន ៖[9]

១. ចាត់វិធានការបន្ទាន់ ។
២. សរសេរលិខិតលើកឡើងជុំវិញករណីរំលោភបំពាន ។
៣.ចេញសេចក្ដីថ្លែងការណ៍ជាសាធារណៈ។
៤. បញ្ចូលព័ត៌មានដែលមានលើកឡើងក្នុងរបាយការណ៍ប្រចាំឆ្នាំ ឬ របាយការណ៍តាមវិស័យរបស់អ្នករាយការណ៍ពិសេស។

វិធានការបន្ទាន់គឺជាសេចក្ដីអំពាវនាវផ្ញើទៅកាន់រដ្ឋនានាពីសំណាក់អ្នកកាន់អាណត្តិនៃអង្គការសហប្រជាជាតិនៅពេលដែលករណីរំលោភបំពានមានសភាពធ្ងន់ធ្ងរ និងមានពាក់ព័ន្ធនឹងការបាត់បង់ជីវិតមនុស្ស ឬបន្តប៉ះពាល់ដល់ជនរងគ្រោះ ដែលជាទូទៅស្នើឱ្យមានការឆ្លើយតបពីរដ្ឋនានាក្នុងរយៈពេល៣០ថ្ងៃ។ ប្រសិនបើមិនបន្ទាន់ទេ អាចផ្ញើលិខិតលើកឡើងនូវករណីរំលោភបំពាននោះក្នុងសារទំនាក់ទំនងស្នើឱ្យមានការបំភ្លឺពីរដ្ឋទាក់ទងនឹងស្ថានភាពសិទ្ធិមនុស្សក្នុងរយៈពេល៦០ ថ្ងៃ។

*២. ការឆ្លើយតបទៅនឹងសំណើសុំជាតុចូលដើម្បីបញ្ចូលក្នុងរបាយការណ៍*

ដូចគ្នាជាមួយនីតិវិធីពិសេសដទៃទៀតដែរ អ្នករាយការណ៍ពិសេសត្រូវបានតម្រូវឱ្យបញ្ជូនរបាយការណ៍ប្រចាំឆ្នាំទៅកាន់ក្រុមប្រឹក្សាសិទ្ធិមនុស្ស និងមហាសន្និបាតដែលរបាយការណ៍នោះមានលើកឡើងនូវសកម្មភាព

[8] ប័ណ្ណព័ត៌មាននៃការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស ស្ដីពី "សារទំនាក់ទំនង" ចេញផ្សាយនៅឆ្នាំ២០២០ https://bit.ly/3bHuS2V
[9] ប្រភពខាងលើ

នានាទាក់ទងនឹងអាណត្តិការងាររបស់អ្នករាយការណ៍ពិសេស ដោយមានភ្ជាប់មកជាមួយនូវអនុសាសន៍ និងសំណើផ្សេងៗទាក់ទងនឹងវិធីសាស្ត្រក្នុងការលើកកម្ពស់ និងការការពារសេរីភាពក្នុងការជួបប្រជុំនិងចងក្រងសមាគមឱ្យកាន់តែប្រសើរ។[10] បន្ថែមលើនេះ ពេលខ្លះអ្នករាយការណ៍ពិសេសផ្តល់ជូនរបាយការណ៍តាមវិស័យផងដែរ ដូចជា របាយការណ៍ឆ្នាំ២០១៩ របស់ពួកគាត់ស្តីពី *"ការភ្ជាប់ទំនាក់ទំនងរវាងការបំបិទលំហសេរីភាពរបស់សង្គមស៊ីវិល ភាពក្រីក្រ គោលនយោបាយជាតិ និងការអនុវត្តសិទ្ធិជួបប្រជុំនិងចងក្រងសមាគម"*។[11]

ដើម្បីទទួលបានព័ត៌មានសម្រាប់បញ្ចូលក្នុងរបាយការណ៍ទាំងនេះ អ្នករាយការណ៍ពិសេសផ្ញើកម្រងសំណួរអំពីប្រធានបទជាក់លាក់ ស្នើសុំធាតុចូលពីតួអង្គសង្គមស៊ីវិល ដែលកម្រងសំណួរទាំងនោះអាចស្វែងរកបាននៅលើគេហទំព័រអ្នករាយការណ៍ពិសេសនៅត្រង់ចំណុច "ស្នើសុំធាតុចូល"។ តួអង្គសង្គមស៊ីវិលអាចឆ្លើយតបសំណួរទាំងនេះជាការរួមវិភាគទានដល់របាយការណ៍របស់អ្នករាយការណ៍ពិសេស។ ជាការសំខាន់នោះគឺថាសំណើសុំធាតុចូលទាំងនេះ ជាទូទៅមានការកំណត់ចំនួនពាក្យ និងកាលបរិច្ឆេទច្បាស់លាស់ ដែលមានផ្សព្វផ្សាយនៅលើគេហទំព័រ។[12] ការឆ្លើយតបទៅនឹងសំណើសុំធាតុចូល អាចផ្ញើសារអេឡិចត្រូនិចដោយផ្ទាល់ទៅកាន់អ្នករាយការណ៍ពិសេសតាមរយៈអាសយដ្ឋាន freeassembly@ohchr.org ។

## *៣.មធ្យោបាយផ្សេងៗដើម្បីចូលរួមជាមួយអ្នករាយការណ៍ពិសេស*

បន្ថែមលើលទ្ធភាពនៃការចូលរួមដែលបានលើកឡើងខាងលើ តួអង្គសង្គមស៊ីវិលអាចចូលរួមជាមួយអ្នករាយការណ៍ពិសេស និងការងាររបស់ពួកគាត់ តាមវិធីក្រៅផ្លូវការផ្សេងទៀតៈ

- ផ្ញើសារអេឡិចត្រូនិចទៅកាន់អ្នករាយការណ៍ពិសេសដោយផ្ទាល់ៈ ដើម្បីលើកឡើងអំពីបញ្ហានានាទាក់ទងនឹងសិទ្ធិជួបប្រជុំនិងចងក្រងសមាគម ឬស្វែងរកព័ត៌មានបន្ថែមពីមធ្យោបាយក្នុងការទំនាក់ទំនង
- ទស្សនកិច្ចក្នុងប្រទេសៈ តស៊ូមតិធ្វើយ៉ាងណាឱ្យរាជរដ្ឋាភិបាលកម្ពុជាទទួលសំណើពីអ្នករាយការណ៍ពិសេសដើម្បីមកធ្វើទស្សនកិច្ចក្នុងប្រទេស

**អាសយដ្ឋានសម្រាប់ផ្ញើទំនាក់ទំនងជាមួយអ្នករាយការណ៍ពិសេស**

លោក ក្លេម៉ិន នីយ៉ាឡេតសូហ្ស៊ី វ៉ូល
កាន់អាណត្តិជាអ្នករាយការណ៍ពិសេសស្តីពីសិទ្ធិជួបប្រជុំដោយសន្តិវិធីនិងចងក្រងសមាគម វិមានសហប្រជាជាតិ (Palais des Nations) គជ-១២១១ ទីក្រុងហ្សឺណែវ ១០ ប្រទេសស្វីស
សារអេឡិចត្រូនិចៈ freeassembly@ohchr.org
ទូរសារៈ + ៤១ ២២ ៩១៧ ៩០០៦

[10] អាចស្វែងរករបាយការណ៍ប្រចាំឆ្នាំនេះនៅទីនេះ https://bit.ly/3bIsNUh។

[11] ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស អ.ស.ប "របាយការណ៍អ្នករាយការណ៍ពិសេស" ចេញផ្សាយនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៩ UN Doc A/74/349 ទំព័រ ១៩ https://undocs.org/A/74/349។ សម្រាប់ព័ត៌មានបន្ថែមអំពីបេកគំហើញរបាយការណ៍អ្នករាយការណ៍ពិសេស សូមមើលសលាកបត្រព័ត៌មានស្តីពីអ្នករាយការណ៍ពិសេសស្តីពីសិទ្ធិជួបប្រជុំដោយសន្តិវិធី និងចងក្រងសមាគម ផលិតដោយ ម.ស.ម.ក (ខែកក្កដា ឆ្នាំ២០២០) https://bit.ly/2ZFMUhh។

[12] អាចស្វែងរកផ្នែកសំណើសុំធាតុចូលនៅទីនេះ https://bit.ly/3igNdWX ។

- អ្នករាយការណ៍ពិសេសរៀបចំការជួបប្រជុំ សិក្ខាសាលា និងការពិគ្រោះយោបល់ជាប់លាប់អំពីប្រធានបទពាក់ព័ន្ធនឹងអាណត្តិការងាររបស់ពួកគាត់ដែលសង្គមស៊ីវិលអាចចូលរួម[13]បាន
- អញ្ជើញអ្នករាយការណ៍ពិសេសចូលរួមព្រឹត្តិការណ៍ ឬគំនិតផ្តួចផ្តើមណាមួយរបស់អ្នក។

## ៥. សេចក្តីសន្និដ្ឋាន

ដូចគូសបញ្ជាក់នៅផ្នែក ៣ ខាងលើ ការចូលរួមជាមួយយន្តការនីតិវិធីពិសេសនៃអង្គការសហប្រជាជាតិ រួមទាំង អ្នករាយការណ៍ពិសេស មានសារៈប្រយោជន៍ជាច្រើនសម្រាប់តួអង្គសង្គមស៊ីវិលដែលធ្វើការងារដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្ស។ ប្រទេសកម្ពុជាប្រឈមនឹងបញ្ហាផ្សេងៗក្នុងការការពារ និងការលើកកម្ពស់សេរីភាពជួបប្រជុំនិងចងក្រងសមាគម[14] ហើយ ម.ស.ម.ក ជំរុញឱ្យតួអង្គសង្គមស៊ីវិលប្រើប្រាស់សលាកបត្រព័ត៌មាននេះដើម្បីចូលរួម និងសហការជាមួយអ្នករាយការណ៍ពិសេសដើម្បីជាប្រយោជន៍ដល់ការការពារសិទ្ធិជួបប្រជុំនិងចងក្រងសមាគមនៅក្នុងប្រទេស។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងលោក សួន យុធ្យា នាយកផ្នែកតស៊ូមតិ នៃ ម.ស.ម.ក តាមរយៈទូរស័ព្ទៈ + ៨៥៥ (០) ៨៨ ៨១ ៤២ ៧៨៣ ឬ សារអេឡិចត្រូនិច** yuthyia@cchrcambodia.org។

[13] អ្នកអាចស្វែងព្រឹត្តិការណ៍បច្ចុប្បន្នរៀបចំដោយអ្នករាយការណ៍ពិសេសលើគេហទំព័រខាងលើដដែលនោះក្រោមផ្នែក "សកម្មភាព"។

[14] សម្រាប់ព័ត៌មានបន្ថែមអំពីសេរីភាពក្នុងការជួបប្រជុំនិងចងក្រងសមាគមនៅកម្ពុជា សូមមើលសលាកបត្រព័ត៌មានរបស់ ម.ស.ម.ក (លេខយោង១១)។